# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ខេត្តសៀមរាប**

លេខៈ .........២០៦.................មកប

**ជម្រាបមក**

**លោកនាយក ជី អេវៀរី (វិស័យទេសចរណ៍)**

អាសយដ្ឋាន សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។
**យោង** ៖ លិខិតលេខ ២០០៥២៦២៣០០ ចុះថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ជី អេវៀរី ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន៥០នាក់ (ស្រី ២២នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ៥០នាក់ (ស្រី២២នាក់) រយៈពេលចំនួន ៣០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ ក្នុងនោះ៖

- កម្មករនិយោជិតចំនួន ៤៣ នាក់ (ស្រី ១៩ នាក់) ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ៤០ដុល្លារអាមេរិកក្នុងមួយខែ។
- កម្មករនិយោជិតចំនួន ៧ នាក់ (ស្រី ៣ នាក់) មិនទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល។

ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់ កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោកនាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី **លោកនាយក** ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ)មុនថ្ងៃចូលធ្វើការ ហើយ **លោក** ត្រូវទទួលខុសត្រូវបង់ជួសកម្មករនិយោជិតទៅតាមចំនួនប្រាក់ឧបត្ថម្ភបានផ្ទេរកម្មករនិយោជិត ដែលបានចូលធ្វើការមុនកំណត់ទាំងនេះ។ ក្នុងករណីចាំបាច់ **លោក** អាចស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់បានចំនួន ១លើក។ ករណីលើសពី១លើក **លោក** ត្រូវទទួលខុសត្រូវចេញប្រាក់ឧបត្ថម្ភជំនួសរាជរដ្ឋាភិបាលឱ្យទៅកម្មករនិយោជិតដែលនៅសល់រហូតដល់បញ្ចប់ការព្យួរកិច្ចសន្យាការងារ។

អាស្រ័យដូចនេះ សូម **លោកនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោកនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃចន្ទ១០កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
សៀមរាប ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២០

**ត.ប. រដ្ឋមន្ត្រី**
**ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ចំនួ សុខុមបិក្កា**

ចម្លងជូនៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលខេត្ត